Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ភ្នំពេញ, ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣

**លទ្ធផលវេទិកា នៅខេត្តកំពង់ចាម**
**"កំណែទម្រង់ការបោះឆ្នោត និងលំហរប្រជាធិបតេយ្យនៅកម្ពុជា"**

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) ក្រោមកិច្ចសហការជាមួយបណ្តាអង្គការ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានរៀបចំវេទិកាមួយ ស្តីអំពី "**កំណែទម្រង់ការបោះឆ្នោត និងលំហរប្រជាធិបតេយ្យនៅកម្ពុជា (FOREDS)**" នៅ **ខេត្តកំពង់ចាម** កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៣ ដោយមានការចូលរួមពីតំណាងគណបក្សនយោបាយ តំណាងគ.ជ.បខេត្ត អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធប្រមាណ **៨២នាក់**។

វេទិកានេះរៀបចំឡើងក្នុងគោលបំណង ដើម្បីឲ្យភាគីដែលពាក់ព័ន្ធបានលើកឡើង និងជជែកពីបញ្ហាដែលទាក់ទងទៅនឹងការបោះឆ្នោត និងប្រជាធិបតេយ្យនៅកម្ពុជា ហើយស្វែងរកនូវអនុសាសន៍ គោលនយោបាយដែលបានពិភាក្សាចែកជូនដល់អ្នកចូលរួម និងបញ្ជូនអនុសាសន៍ទាំងនោះទៅស្ថាប័នដែលពាក់ព័ន្ធក្នុងការដោះស្រាយ។

| **អនុសាសន៍ពី វេទិកា FOREDS នៅខេត្តកំពង់ចាម (ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៣)** |
|---|
| **១. ការជ្រើសរើស និងការពង្រឹងសមត្ថភាពមន្ត្រីបោះឆ្នោតនៅថ្នាក់ឃុំ និងថ្នាក់ការិយាល័យបោះឆ្នោត**<br>• មនុស្សឯករាជ្យពិតប្រាកដ មិនស្ថិតក្នុងគណបក្សនយោបាយ<br>• ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយក្នុងការជ្រើសរើសមន្ត្រី<br>• មានការយល់ដឹងផ្លូវច្បាប់ និងនីតិវិធីបោះឆ្នោត<br>• ជាមនុស្សមានបទពិសោធន៍ផ្នែកខាងការបោះឆ្នោត<br>• ជាមនុស្សមានក្រមសីលធម៌ល្អ<br>• បណ្តុះបណ្តាលមន្ត្រីបោះឆ្នោត<br>• បើកវគ្គបណ្តុះបណ្តាល នីតិវិធីការបោះឆ្នោត ជាសាធារណៈ<br>• ត្រូវផ្តល់ថវិកាសមរម្យសំរាប់មន្ត្រីបោះឆ្នោត<br>• ជ្រើសរើសមនុស្សមានទីលំនៅនៅទីតាំងភូមិ ឃុំ នៅក្នុងការិយាល័យបោះឆ្នោត<br>• បង្កើតច្បាប់ដាក់ពិន័យចំពោះមន្ត្រីដែលមិនអនុវត្តតាមតួនាទីកំឡុងម៉ោងការងារ |

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

**២. ការទប់ស្កាត់ និងបង្ការអំពើហិង្សាពេលបោះឆ្នោត**

- ក្នុងច្បាប់បោះឆ្នោត ហាមមិនឱ្យសមត្ថកិច្ចនៅជិតការិយាល័យបោះឆ្នោតចំងាយ១០០ម៉ែត្រ
- បើមានបញ្ហាកើតឡើងទើបប្រធានការិយាល័យស្នើសុំ ទើបសមត្ថកិច្ចមានសិទ្ធិចូល
- រាល់ពាក្យបណ្តឹងពាក់ព័ន្ធនឹងការងារបោះឆ្នោតជាសមត្ថកិច្ចរបស់ គ.ជ.ប ជាអ្នកដោះស្រាយ
- មិនឱ្យមេភូមិនៅពីឈរមុខការិយាល័យបោះឆ្នោត
- មិនឱ្យអ្នកស្រវឹងចូលរួមការិយាល័យបរិវេណបោះឆ្នោត
- មិនឱ្យយកអាវុធជាតិផ្ទុះចូលការិយាល័យបរិវេណបោះឆ្នោត
- មិនឱ្យពាក់ស្លាកគណបក្សនយោបាយក្នុងបរិវេណការិយាល័យបោះឆ្នោត
- ហាមយកឡានមន្ត្រីរាជការ ឬរដ្ឋ ដឹកអ្នកបោះឆ្នោតចូលការិយាល័យបោះឆ្នោត
- កម្លាំងការពារសន្តិសុខត្រូវបានរៀបចំឋានានុក្រមនៃច្បាប់បោះឆ្នោតបានកំណត់ (នគរបាល ប៉េអឹម យោធា)
- ការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ គ្រប់ស្រទាប់វណ្ណៈ គ្រប់គណបក្សនយោបាយឱ្យបានយល់អំពីច្បាប់បោះឆ្នោត ពីតម្លៃបានមកពីការបោះឆ្នោតដែលទទួលបាននូវឧត្តមប្រយោជន៍ជាតិ
- ការបោះឆ្នោតទទួលបានជោគជ័យ មានតម្លាភាព ប្រសិទ្ធិភាព និងយុត្តិធម៌ គ្មានអំពើហិង្សា លុះត្រាណាមានការចូលរួមទាំងអស់គ្នា
- រាល់ភ្នាក់ងារស៊ើបអង្កេត និងភ្នាក់ងារធ្វើការនៅក្នុងការិយាល័យ មិនត្រូវនិយាយប៉ះពាល់គណបក្សនយោបាយណាមួយ
- ហាមមិនឱ្យអ្នកឡូឡាចូលរំខានក្នុងបរិវេណបោះឆ្នោត
- ហៅអ្នកដឹកនាំរបស់ប្រធានគណបក្សនយោបាយទាំងអស់ មកវែកញែកពិភាក្សាអំពីការដោះស្រាយបញ្ហាអំពើហិង្សានយោបាយ
- គ.ជ.ប ត្រូវពង្រឹងផ្នែកៈ
  - រដ្ឋបាល
  - បម្រើអប់រំសាធារណជន
  - កិច្ចការអប់រំនឹងត្រូវផ្សព្វផ្សាយ
  - សេវាកម្មច្បាប់
  - ប្រតិបត្តិ

**៣. ដំណោះស្រាយបណ្តឹងទាក់ទងនៅនឹងការបោះឆ្នោត**

ជំរើសទី ១

- ជ្រើសរើសគណៈកម្មការបន្ថែម ( NGO ) ហៅថា **គណៈកម្មាធិការយុត្តិធម៌បោះឆ្នោត** មានភារកិច្ចសំរាប់ដោះស្រាយពាក្យបណ្តឹងតែមួយគត់
- គណៈកម្មាការនេះមានចាប់ពីឃុំ សង្កាត់ (CEC) ទៅ PEC ហើយប្រើប្រាស់ពេលវេលាយ៉ាងតិច ៥ទៅ៧ ថ្ងៃសំរាប់ CEC និង PEC
- ថវិកាសំរាប់ទ្រទ្រង់គណៈកម្មាធិការនេះ ដោយ (NGO)

| ជំរើសទី ២ |
| --- |
| • គ.ជ.ប ត្រូវផ្តល់អំណាចសិទ្ធិសម្រេចដល់គណៈកម្មាការយុត្តិធម៌បោះឆ្នោតមានភារកិច្ចដោះស្រាយពាក្យបណ្តឹងថ្នាក់ PEC<br>• គណៈកម្មាការយុត្តិធម៌មានសិទ្ធិស៊ើបអង្កេតទោះជាគ្មានពាក្យបណ្តឹងក៏ដោយ<br>• ចំពោះបទល្មើសព្រហ្មទណ្ឌបោះឆ្នោតត្រូវបញ្ចូលក្នុងច្បាប់បោះឆ្នោត |
| **៤. សេរីភាពក្នុងការបញ្ចេញមតិ និងប្រមូលផ្តុំ** |
| • ការបញ្ចេញមតិដោយមានវេទិកាត្រឹមត្រូវ ឧទាហរណ៍. ពេលវេលា ទីកន្លែង ធនធាន<br>• ត្រូវផាកពិន័យចំពោះជនណា ក្រុមណាដែលមានចេតនារំខានចំពោះដំណើរនៃការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ<br>• ស្នើសុំឲ្យមានការអប់រំដល់ប្រជាពលរដ្ឋកុំឲ្យមានការហែកខិតបត្រដែលបានផ្សព្វផ្សាយ<br>• គ្រប់ប្រព័ន្ធផ្សព្វផ្សាយត្រូវមានសមធម៌សម្រាប់ការផ្សព្វផ្សាយគ្រប់គណបក្សនយោបាយ<br>• ការបញ្ចេញមតិត្រូវមានក្រមសីលធម៌ និងមានដែនកំនត់នៃលក្ខខណ្ឌច្បាប់<br>• ផ្តល់សេរីភាពឲ្យប្រជាពលរដ្ឋដើម្បីបញ្ចេញមតិក្នុងគណបក្សនយោបាយ រាល់វេទិកាសាធារណៈផ្សេងៗ |
| **៥. ហិរញ្ញវត្ថុគណបក្សនយោបាយ** |
| • គាំទ្រឲ្យមានច្បាប់ស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយ និងមានទណ្ឌកម្មសម្រាប់អនុវត្តចំពោះអ្នកបំពានច្បាប់នេះ<br>• ត្រូវតែមានកំណត់ចំណូល ចំណាយរបស់គណបក្សនីមួយៗឲ្យបានច្បាស់លាស់<br>• ត្រូវតែមានគណៈកម្មាធិការជាតិ ដើម្បីត្រួតពិនិត្យអំពីប្រភពហិរញ្ញវត្ថុរបស់គណបក្សនយោបាយនីមួយៗ<br>• ត្រូវមានសមាសភាពមកពីគណបក្សដែលមានអសនៈក្នុងសភា ជាសមាជិកគណៈកម្មាធិការត្រួតពិនិត្យហិរញ្ញវត្ថុ<br>• ត្រូវតែប្រកាសហិរញ្ញវត្ថុរបស់គណបក្សនយោបាយនីមួយៗមុនពេលឃោសនាបោះឆ្នោត<br>• ផ្សព្វផ្សាយព័ត៌មានហិរញ្ញវត្ថុរបស់គណបក្សនយោបាយតាមប្រព័ន្ធ វិទ្យុ ទូរទស្សន៍ អ៊ីនធឺណិត កាសែតផ្សេងៗ<br>• រដ្ឋត្រូវតែមានកញ្ចប់ថវិកាមួយជាក់លាក់សម្រាប់ជួយសម្រួលដល់គណបក្សនយោបាយក្នុងយុទ្ធនាការឃោសនាបោះឆ្នោត<br>• អង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ យុវជន មានសិទ្ធិគ្រប់គ្រាន់ ទទួលបាននូវព័ត៌មានអំពីចំណូលចំណាយ និងចូលរួមសង្កេតការណ៍ទៅលើចំណូល និងចំណាយរបស់គណបក្សនយោបាយ |

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង* ៖

*១-លោក **សួន យុជ្យា** / មន្ត្រីតស៊ូមតិ និងច្បាប់ខុមហ្វ្រែល (០៩៧-៥៩-៨៧-២៦៥)*